

# ព្រះបាទត្រសក់ផ្អែម

# PREAHBAT TRAR-SAUK PEU-EM

BW
Books World



## រូបសំណាក់ព្រះបាទត្រសក់ផ្អែម
(Sweet cucumber king)

ពញាជ័យ ព្រះជន្ម៤៥០ឆ្នាំ (បើថា ៤៥៣ឆ្នាំ ទើបត្រូវនឹងរឿងខាងក្រោម) បានឡើយសោយរាជ្យតប្រយូរវង្ស (ប្រែថា ផៅពង្ស ព្រះញាតិ ព្រះញាតិវង្ស) ព្រះបាទសេណករាជទ្រង់ព្រះនាមជាព្រះបាទសម្តេចព្រះរាជឱង្ការ ព្រះបរមរាជាធិរាជជ័យ។ ទ្រង់បានលើកពញាសួស ព្រះអនុជជាសម្តេចព្រះមហាឧបរាជ។ ពញាជ័យនិង ពញាសួសមានដើមកំនើតដូចតទៅនេះ:

Ponhea Chey, who was 450 years old (To be consistent with the story that will read below, the age should have been 453 years old instead), succeeded king Preas-bat Senak-reach and was named Preah-bat Samdech Preahreach-angka Preah Borom Reacheathi-reach Chey. He named Ponhea Suors heir apparent. Below goes the story of the two men.



ពញាជ័យ និងពញាសួស ទាំងពីរនាក់ជាបងប្អូនបង្កើតនឹងគ្នា។ គាត់មានលំនៅនៅខាងទិសនិរតីនៃភ្នំប្រសិទ្ធិ។ អ្នកទាំងពីនាក់នេះ មានរបររកទទួលទានជាអ្នកចំការដាំត្រសក់។ ក្នុងពេលលំហែពីមុខងារធ្វើត្រសក់ហើយ គាត់តែងនាំអ្នកស្រុកលេងមហោស្រព ជាការកំសាន្ត។

Ponhea Chey and Ponhea Suors were brothers, who settled south-west of Phnom Praseth. They earned their living by growing cucumbers. During their free time at the cucumber farm, the two usually had local people joining them inputting on art performance in order to entertain themselves.





ថ្ងៃក្រោយមក ព្រះបាទសេណករាជ ជាអម្ចាស់ផែនដី ស្ដេចទៅសាងព្រះរាជវាំង នៅក្បែរភ្នំប្រសិទ្ធិដែរ។ ពញាជ័យ និងពញាសួស កាលបានដំណឹងនេះហើយ ក៏នាំបងប្អូនបេះត្រសក់ និងនាំល្បែងមហោស្រពទៅថ្វាយព្រះរាជាជារឿយៗ។ ព្រះមហាក្សត្រទ្រង់សព្វព្រះទ័យនឹងត្រសក់គាត់ណាស់។ ទ្រង់មានព្រះបន្ទូលថា៖ "ត្រសក់នេះផ្អែមអស្ចារ្យ ជាងត្រសក់ទាំងឡាយ"។ ទ្រង់បានហាមថា៖ "កុំឱ្យពញាជ័យ និងពញាសួស បេះត្រសក់នោះលក់ដូរ ឱ្យអ្នកណាឱ្យសោះ ឱ្យទុកសម្រាប់តែ ធ្វើជាដង្វាយ ព្រះអង្គតែប៉ុណ្ណោះ"។



Later on, King Senak-reach built a royal palace close to Phnom Praseth. Having known that the king was nearby, Ponhea Chey and Ponhea Suors often brought the cucumbers to offer to the king and organized art performance to entertain him as well. His Majesty was very pleased with the cucumbers, saying: "The cucumbers are sweeter than all others". The king then asked the two brothers not to sell their cucumbers to no one but himself.

ព.ស.១៥២៧ គ. ស. ៩៨៣ ម. ស. ៩០៥ ច.ស.៣៤៥ ក្នុងឆ្នាំមមែបញ្ចស័ក ព្រះបាទបរមបពិត្រ សេណករាជ បរមរាជា ស្តេចសោយរាជ្យបាន៣០ឆ្នាំ។ ពញាជ័យអាយុបាន៤៣៨ឆ្នាំ ពញាសួស អាយុបាន៣៣៨ឆ្នាំ។ ក្នុងគ្រានោះ មានក្របីអ្នកស្រុកម្នាក់បានទំលាយរបងចំការត្រសក់ របស់ពញាជ័យ និងពញាសួស ហើយចូលមកជិះជាន់ស៊ីត្រសក់របស់គាត់អស់ជាច្រើន។ ពញាជ័យ ឃើញដូច្នោះហើយ ក៏យកដុំថ្មចង្ក្រានចោល ដើម្បីដេញបង្អើលសត្វនោះឱ្យជៀសទៅ ដុំថ្មនោះក៏រត់ទៅត្រូវធ្លុះក្របីនោះស្លាប់ទៅ។

In 1527(the Buddhist era), or 983 A.D, in the Year of Goat, His Majesty Preahbat Borom-pit Senak-reach reigned for 30 years. Ponhea Chey aged 438 while Ponhea Suors 338. There was then a buffalo in the village tearing down the cucumber farm fance of Ponhea Chey and Ponhea Suors and came in to destroy and eat many cucumbers. To frighten it off, Ponhea Chey threw a stove stone at the animal. The stone pierced into the buffalo and killed it instantly.





ម្ចាស់ក្របីប្ដឹងដល់ចៅក្រមទាំងឡាយ  អំពីរឿងពញ្ញាជ័យសម្លាប់ក្របីរបស់ខ្លួននេះ។  ចៅក្រមតុលាការកាត់សេចក្ដីឱ្យពញ្ញាជ័យសងក្របីទៅម្ចាស់ក្របីវិញ។ ពញ្ញាជ័យមិនសុខចិត្តដ្បិតថា កាលខ្លួនចោលក្របីនឹងដុំថ្មចង្ក្រាននោះ ខ្លួនមិនប៉ងឱ្យស្លាប់ក្របីនោះទេ  គឺចោលឱ្យគ្រាន់តែ  ក្របីនោះខ្លាចហើយរត់ចេញទៅតែប៉ុណ្ណោះ។  ចៅក្រមកាត់ក្ដីនេះមិនដាច់ស្រេច  ក៏នាំសេចក្ដីនេះទៅប្ដឹងដល់សេនាបតី ។ សេនាបតីក៏កាត់ក្ដីមិន  ដាច់ទៀត ទើបនាំមនុស្សនោះឡើងក្រាបបង្គំទូលព្រះបរមបពិត្រដើម្បីសូមទ្រង់ព្រះរាជវិនិច្ឆ័យឱ្យ។ ព្រះរាជាឱ្យយកដុំក្រាននោះចោលក្របីឯទៀតជាការ ល្បងមើល ។ កាលពញ្ញាជ័យចោលទៅក្របីណា ក្របីនោះក៏ធ្លាយពោះនឹងដុំថ្មនោះ ស្លាប់ទាំងអស់មែន។





The owner of the water buffalo complained to the judge about Ponhea Chey's killing of his animal. The judge ruled that Ponhea Chey had to pay water buffalo back to the man. Ponhea Chey did not agree because he did not mean to kill the animal when he hurled the stove stone at the animal. He only wanted to scare it off. The judge failed to rule, and then took the issue to the supreme commander. Also unable to render judgement, the supreme commander referred the case to the king. The king had the stones hurled at the buffaloes for experiments. One after another, the buffaloes had their belly pierced open after being hit by Ponhea Chey.

ព្រះរាជាទ្រង់ពិសោធឃើញយ៉ាងនេះហើយ ក៏ទ្រង់កាត់សេចក្ដីថា: ក្របីនោះស្លាប់ដោយពញាជ័យមិនមានចិត្តក្លែងសម្លាប់ទេ ពីព្រោះពញាជ័យ មិនបានដឹងថាថ្មនោះជាដែកកាយសិទ្ធទេស្មានថាជាដុំថ្មធម្មតា បានជាចោលទៅត្រូវស្លាប់ដូច្នេះ ។ ហេតុនេះទ្រង់ប្រោសប្រទាន ព្រះរាជវិនិច្ឆ័យថា: ក្របីស្លាប់នេះ ទុកជាកម្មរបស់សត្វចុះយើងនឹងយកទោសពញាជ័យមិនបានទេ។ ទើបទ្រង់ឱ្យពួកជាងយកដុំក្រាននោះទៅរំលាយមើល ។ ជាងយកទៅរំលាយទៅក៏ឃើញថា ថ្មនោះជាដែកកាយសិទ្ធពិតមែន ទើបទ្រង់ព្រះបង្គាប់ឱ្យក្រុមជាងយកដែកនោះទៅផែជាលំពែងមួយ ហើយទ្រង់ប្រគល់ឱ្យពញាជ័យកាន់លំពែងនោះទុក រក្សាចំការ ត្រសក់នោះទុកជាដីចំការលួង ។ ឯលំពែងនោះ សន្មត ហៅថា លំពែងជ័យ ។

After having the experiments carried out, His Majesty the king ruled that the animals were killed, but not because Ponhea Chey genuinely intended to do it. He actually presumed that the stones were simply rocks, not the mighty iron that would be able to kill. So the king ruled that the animals' deaths were their fate and Ponhea Chey was not guilty. The king then got the black-smith to melt the stones, which were found to be real iron. The king ordered the blacksmiths to heat and smite the iron to produce a spear. The king handed it to Ponhea Chey to be used as weapon to guard his cucumber farm, which was considered royal land. The lance was named "Lompeng Chey" (Spear of Chey).







ព.ស. ១៥៣៩-គ.ស. ៩៩៥- ម.ស. ៩១៧ ច.ស. ៣៥៧ ឆ្នាំមមែ សប្តស័ក ព្រះបរមបពិត្រ ព្រះសេណករាជ ទ្រង់មានព្រះជន្មវស្សា ៥៩ឆ្នាំ ទ្រង់សិរីរាជសម្បត្តិបាន៤២ឆ្នាំ ពញាជ័យ មានជន្មាយុជាង៤៥០ឆ្នាំពញាសួស មានជន្មាយុ ៣៥០ឆ្នាំ ។ គ្រានោះ ព្រះបរមបពិត្រ អម្ចាស់ផែនដី ទ្រង់មានព្រះរាជហឫទ័យសង្ស័យថា ពញាជ័យ ពញាសួសនោះ ដាំត្រសក់ សម្រាប់ទុកតែជាដង្វាយទេ ឬមួយគាត់លបដាំឱ្យគេខ្លះដែរ ។ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ វេលាយប់ស្ងាត់ ទ្រង់ក៏ត្រាស់ហៅមន្ត្រី ក្រុមស្និទ្ធព្រះអង្គ ប្រាំមួយប្រាំពីរនាក់ ឱ្យចងព្រះទីនាំងអស្សតរ (អស្សតរ= សេះល្អ សេះលឿន) ថ្វាយ ទ្រង់គង់តម្រង់ទៅចំការត្រសក់ ។

In 1539(the Buddhist era), or 995 A.D, in the year of Goat, Preah Borom-borpit Preah Senak-reach was 59 years old and reigned for 42 years, while Ponhea Chey was over 450 years old and Ponhea Suors 350 years old. His Majesty the king was not confident that Ponhea Chey and Ponhea Suors plant the cucumbers and kept them as offering only for him. The two men might offer them to other people. In order to check if he was right, one night the king had a group of devoted officials getting a smart horse for him to ride to the cucumber farm.





ខណៈនោះលំពែងជ័យ ក៏ត្រូវចំលើព្រះបរមបពិត្រ បណ្ដាលឱ្យទ្រង់ព្រះសុគត នៅជើងដំបូកក្នុងចំការនោះទៅ។ ហេតុនេះហើយបានជាដំបូកនោះជាប់ឈ្មោះហៅថា " ដំបូកចាក់ស្ដេច " រៀងមកដល់សព្វថ្ងៃនេះ។ លុះព្រឹកឡើងសេនាបតីមន្ត្រីទាំងពួងបានឮដំណឹងនេះហើយ ក៏នាំគ្នាទៅលើកព្រះបរមសព ដាក់ក្នុងព្រះកោដ្ឋ យកទៅដំកល់ទុកធ្វើបុណ្យតាមប្រពៃណី។

The mighty spear hit the king and killed him at the foot of the mound. The mound has until now been literally known as "the mound that stabbed the king". Having learned about the event, the high-ranking official and officers went to the place and brought the king body back to keep in the royal urn and to hold the ritual funeral.





បន្ទាប់មក សេនាបតីមន្ត្រីទាំងពួងជំនុំគ្នាថា : ព្រះសីហៈកុមារ ដែលជាព្រះរាជបុត្រនៃព្រះបាទសេណករាជនោះក៏ទ្រង់ក្ស័យព្រះជន្មនៅឯស្រុកលាវ មុនសម្តេចព្រះបិតាទៅហើយ ឥឡូវនេះ ព្រះអង្គគ្មានព្រះរាជបុត្រនឹងថ្វាយសោយរាជ្យប្រយូរវង្សបានទេ។ លុះជំនុំវែងឆ្ងាយទៅមន្ត្រីទាំងពួងយល់ឃើញថា :ពញាជ័យ ពញាសួស ទាំងពីរនាក់នេះ អាយុក៏វែង ហើយអាវុធរបស់គាត់នោះក៏មុតក្រៃលែង លើសអាវុធរបស់ជនទាំងពួង ។ ពូជពង្ស របស់គាត់ ក៏ជាប់ក្នុងព្រះរាជត្រកូលផងដែរ ។

The senior officials conferred that Prince Sei-hak Koma, the son of Preas-bat Senak-reach, already died in Laos, so the king had no successor. After a long discussion, all the officials felt that Ponhea Chey and Ponhea Suors had long life and also got a sharper weapon than other people's. Their family also had a royal descent.



មិនតែប៉ុណ្ណោះសោតបណ្ដារាស្ត្រទាំងឡាយ ក៏ស្រឡាញ់គាត់ បាននាំគ្នាមកពីស្រុកជិតស្រុកឆ្ងាយ សុំចុះចូលគាត់ជាច្រើនឃើញថា គួរតែយើងអញ្ជើញគាត់ឱ្យឡើងសោយរាជ្យទៅ។ លុះគិតព្រមគ្នាដូច្នេះហើយនាំគ្នារៀបក្បួនដែលសម្រាប់ហែព្រះមហាក្សត្រនោះទៅអញ្ជើញ ពញាជ័យ ពញាសួស ឱ្យមកសោយរាជ្យ ជាតំណប្រយូរវង្ស។ ព្រះអង្គទាំងពីរព្រះអង្គ ប្រកែកមិនព្រមទទួលរាជសម្បត្តិ ជាស្ដេច និង ជាឧបរាជសោះទេ ព្រោះទ្រង់ស្ដាយស្ម័គ្របក្សពួក និងល្បែងមហោស្រពទាំងឡាយ។

They were also admired by local people who travelled from near and distant villages to align themselves with the two brothers, and wished that one of them be crowned. After having come up with the idea, they set off in a spectacular royal convoy to invite the two brothers to succeed the throne. The two refused to accept the request to become king and heir apparent respectively because they very much missed their colleagues and the art performance.



ខណៈនោះមន្ត្រីទាំងឡាយ ដឹងព្រះរាជហឫទ័យ ហើយក៏ក្រាបទូលអង្វរថា: សូមឱ្យតែព្រះអង្គទ្រង់ព្រមទទួលសោយរាជ្យចុះ ខ្លួនទាំងអស់គ្នានឹងនាំ ប្រដាប់ល្បែងមហោស្រពទាំងប៉ុន្មាន យកទៅទុកក្នុងព្រះរាជនគរ សម្រាប់លេងថ្វាយរាល់ថ្ងៃជាលំហែព្រះកាយ ។ ព្រះអង្គទាំងពីរព្រះអង្គទ្រង់ព្រះសណ្ដាប់ហើយ ក៏ទទួលសេចក្ដីអញ្ជើញរបស់សេនាបតី មន្ត្រីទាំងអស់នោះ ។ សេនាបតីមន្ត្រីទាំងនោះអញ្ជើញសម្ដេចពញាជ័យ ឱ្យគ្រងរាជ្យ (ទទួលរក្សារាជ្យជាបណ្ដោះអាសន្នសិនទំរាំដល់ ថ្ងៃអភិសេក) ជាស្ដេចនិងអញ្ជើញពញាសួសឱ្យគ្រងរាជ្យ ជាឧបរាជ



ហើយក៏អញ្ជើញស្ដេចត្រាច់ចុះ ព្រះទីនាំងនាវាព្រមទាំងក្បួនហែ ចូលស្ថិតនៅក្នុង
ព្រះមហានគរ ។ បីឆ្នាំក្រោយមក ទើបធ្វើពិធីរាជភិសេកតាមទំនៀម ។

All the senior officials could tell the feeling of the two, and they then said: "Our dear men! Please accept our request for you to ascend the throne. We will bring in the palace all the art stuff and put on art performance every day in order to entertain you". The two brothers then accepted the request. All the senior officials and officers invited Ponhea Chey to ascend the throne on a temporary basis , waiting for the auspicious day to come when the coronation could start. They invited the two men to get on the boats and headed for the palace. Three years later, the coronation was organized in accordance with the royal custom.





លុះបានសោយរាជ្យ (បានឡើងជាក្សត្រិយ៍គ្រងរាជពេញទីហើយ) ហើយព្រះបរមរាជាធិរាជអង្គជ័យ ទ្រង់ឱ្យយកលំពែងជ័យនោះ ទៅដំកល់ជាមួយនឹងគ្រឿងព្រះបញ្ចក្សេត្រ ។ ទ្រង់ត្រាស់បង្គាប់ឱ្យក្រុមមហោស្រពផ្លាស់ប្តូរ គ្នាលេងឱ្យអ្នកស្រុកមើលជាទីថ្កើងថ្កាន ហើយទ្រង់ត្រាស់ឱ្យសាងប្រាសាទ សួរព្រ័ត្រមួយ យោលទោងមួយ បិទពួនមួយ គ្រប់ទ្វារនគរ សម្រាប់ទតល្បែង។ អស់រាស្ត្រប្រុសស្រី សុខសប្បាយ ថ្កើងថ្កាន ដោយបុណ្យបារមី របស់ព្រះអង្គពន់ប្រមាណណាស់ ។

After being crowned, Preah Borom Reacheathi-reach Chey had the mighty lance stored together with the other royal stuff. He also ordered the royal art troupes to take turn to entertain his subjects and the erection of Suor Proat temple, Yol-tong temple and Bet-puon temple at the kingdom entrances to spend time enjoying the games. The subjects, men and women, lived a happy and prosperous life because of His majesty might.



សេនាបតី មន្ត្រីរាស្ត្រ ទាំងពួង ឃើញព្រះអង្គមានបុណ្យមានព្រះជន្មវែងក្រៃលែង លើសជនទាំងពួងដូច្នោះក៏ក្រាបថ្វាយបង្គំទូល សូមព្រះរាជទានព្រះរាជបញ្ញត្តិថា: បើមានមង្គលការអ្វីៗ សូមឱ្យអ្នកមង្គលការនេះឱ្យពរថា :"ជ័យហោង សួស្តីហោង " ដើម្បីឱ្យបានសេចក្តីសុខ និងអាយុយឺនយូរ វែងដូចព្រះអង្គផងព្រះបរមពិត្រយល់ថា: ការសុំនេះជាប្រយោជន៍ដល់រាស្ត្រប្រជារបស់ព្រះអង្គផង ហើយជាកិត្តិយសដល់ព្រះអង្គទៀត ដូច្នេះទ្រង់ក៏ព្រះរាជា នុញ្ញាតតាមសុំ។ អាស្រ័យហេតុនេះហើយ បានជាក្នុងមង្គលការទាំងឡាយសព្វថ្ងៃនេះ ជនទាំងពួងតែងឱ្យពរ គូស្វាមីភរិយាថ្មីថា: ជ័យហោង សួស្តីហោង រឿងដរាបមក។

Having been impressed by the longer life the king could live than other ordinary people, the high ranking officials and officers as well as the subjects humbly asked the king to decree that whenever a nuptial rite took place, the blessing ovation "Chey Haung! Suors Haung! " had to be shouted out so that the couple might live as happily and long as the king did. His Majesty felt that the proposal was for the benefits of his subjects and also his privilege, so he agreed to the request. Hence, during all contemporary nuptial ceremonies the invited guests often shout in ovation at the groom and bride: "Chey Haung! Suors Haung! ".



ចប់

The End